# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

## ជំពូក ០៧

## តម្រូវការនានានៃការបោសសម្អាត
## សំណល់ជាតិផ្ទុះពីសង្គ្រាម

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
អគារប្ញើផ្លូវលេខ ២៧៣កែង៥១៦សង្កាត់ទួលសង្កែខណ្ឌទួលគោកក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១| ០២៣-៨៨១-៤៩២
អ៊ីមែល: deth@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

## មាតិកា.....ក


**សេចក្ដីផ្ដើម** ..... ១
**តម្រូវការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម** ..... ២
**១.ទ្រនាប់ទ្រាយ** ..... ២
**២.វាក្យស័ព្ទនិងនិយមន័យ** ..... ២
**៣.តម្រូវការជាក់លាក់សម្រាប់ការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម** ..... ២
**៤-ការធ្វើគំរោងផែនការបោសសម្អាតថ្នាក់ជាតិ** ..... ៣
៤.១សុពលភាពនៃភារកិច្ចបោសសម្អាត និងការជ្រើសរើសភារកិច្ច ..... ៣
៤.២ ការធ្វើផែនការនៃការងារបោសសម្អាត..... ៣
**៥. ការទំនាក់ទំនងសហគមន៍** ..... ៣
**៦. គុណភាពការបោសសម្អាត** ..... ៤
**៧. កិច្ចសន្យា និងកិច្ចព្រមព្រៀងបោសសម្អាត** ..... ៤
**៨. ការទទួលខុសត្រូវ និងភាតព្វកិច្ច**..... ៥
៨.១ ការទទួលខុសត្រូវរបស់អាជ្ញាធរមីន ..... ៥
៨.២ ការទទួលខុសត្រូវរបស់ប្រតិបត្តិករ ..... ៥
៨.៣ ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ ..... ៥
៨.៤ ការទទួលខុសត្រូវរបស់អតិថិជន ..... ៦

## សេចក្តីផ្តើម

គោលដៅនៃការបោសសម្អាតនៅប្រទេសកម្ពុជា គឺជាការកំណត់អត្តសញ្ញាណ និងការយកចេញ ឬការបំផ្លាញចោលនូវគ្រាប់មីន និងគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះទាំងអស់ ពីតំបន់ជាក់លាក់ណាមួយឲ្យបានដល់ជម្រៅ និងគុណភាពដែលបានកំណត់។ ផ្ទៃដី និងជម្រៅដែលត្រូវបោសសម្អាត ត្រូវសម្រេចដោយការសិក្សាវាយតំលៃលើការប្រើប្រាស់ដី ក្រោយពេលបោសសម្អាតរួច ការស្រាវជ្រាវបច្ចេកទេស ឬព័ត៌មានដែលអាចទុកចិត្តបានផ្សេងទៀត ដែលអាចកំណត់វិសាលភាពនៃតំបន់ និងជម្រៅនៃការគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ។

ការសិក្សាវាយតំលៃលើតម្រូវការបោសសម្អាត សំដៅជានាថាភារកិច្ចដ៏សមរម្យត្រូវបានជ្រើសរើសសម្រាប់កិច្ចប្រតិបត្តិការបោសសម្អាត ការប្រើប្រាស់ដីក្រោយពេលបោសសម្អាតរួច និងអ្នកទទួលផលត្រូវបានកំណត់នូវកម្រិតគ្រោះថ្នាក់ពិតប្រាកដ ព័ត៌មានបច្ចេកទេស និងវិសាលភាពនៃការងារត្រូវបានបញ្ជាក់ ព្រមទាំងកត់ត្រាច្បាស់លាស់ ហើយដំណើរការគ្រប់គ្រងគុណភាព និងប្រសិទ្ធភាពនៃការបោសសម្អាតត្រូវបានអនុវត្ត។

អ្នកទទួលផលត្រូវតែទទួលបានការជឿទុកចិត្តថា ដីដែលបានបោសសម្អាតរួចមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់របស់ខ្លួន។ ចំណុចនេះទាមទារអោយមានប្រព័ន្ធគ្រប់គ្រងនីតិវិធីបោសសម្អាត និងដំណើរការគ្រប់គ្រងគុណភាពដោយបានចងក្រងជាឯកសារច្បាស់លាស់ ដែលមានលក្ខណៈសមស្របប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ គោលបំណងនៃការប្រើប្រាស់ដីបោសសម្អាតរួច ត្រូវបានរៀបចំឡើងតាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍អ្នកទទួលផល និងគណៈកម្មាការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន។ សហគមន៍មូលដ្ឋាន និងអតិថិជនគួរទទួលបាននូវការពន្យល់សង្ខេបជារឿយៗ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការបោសសម្អាតពីប្រតិបត្តិករបោសសម្អាតដែលសកម្មភាពនេះ គឺជាវិធានការនៃការកសាងទំនុកចិត្តប្រកបដោយប្រសិទ្ធភាព។

ការគ្រប់គ្រងគុណភាពពីផ្នែកខាងក្រៅនៃសកម្មភាពកម្ចាត់មីននៅកម្ពុជា រួមមានការផ្តល់ប័ណ្ណទទួលស្គាល់ការផ្តល់អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យទៅលើប្រតិបត្តិករបោសសម្អាតនៅមុន និងក្នុងអំឡុងពេលនៃដំណើរការបោសសម្អាត ហើយអាជ្ញាធរមីនក៏ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងគុណភាពផ្ទៃក្នុងរបស់ប្រតិបត្តិករបោសបោសសម្អាតផងដែរ។ ដើម្បីសម្រេចបាននូវគោលដៅនេះ បណ្តាប្រតិបត្តិករបោសសម្អាតមីនត្រូវរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមួយប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើត និងថែរក្សានីតិវិធីក្នុងការដាក់ឲ្យអនុវត្តប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ នីតិវិធីនៃការគ្រប់គ្រងត្រូវតែមានតម្លាភាព និងអាចធ្វើសវនកម្មបាន។ គោលបំណងនៃដំណើរការគ្រប់គ្រងគុណភាព គឺដើម្បីអោយអាជ្ញាធរមីនអាចទទួលបាននូវកម្រិតនៃការទុកចិត្តលើដីដែលបានបោសសម្អាតរួច ថាមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។ គុណភាពនៃការបោសសម្អាត ត្រូវតែអាចទទួលយកបានទាំងអាជ្ញាធរមីន និងសហគមន៍មូលដ្ឋានដែលទទួលផល ព្រមទាំងអាចវាស់វែង ផ្ទៀងផ្ទាត់ និងបានកត់ត្រាជាក់លាក់។

ដំណើរការរួមគ្នានៃការកំណត់អត្តសញ្ញាណលើតម្រូវការនៃការប្រើប្រាស់ដី និងការគ្រប់គ្រងគុណភាពនៃការងារបោសសម្អាត និងជួយក្នុងការទទួលបាននូវកម្រិតនៃការជឿជាក់ដែលអាចទទួលយកបានថាដីនោះ ត្រូវបានបោសសម្អាតដោយអនុលោមតាមកម្រិតស្តង់ដាខ្ពស់ និងមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។

# តម្រូវការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម

## ១.ទំហំវិសាលភាព

ស្តង់ដានេះកំណត់អត្ថន័យនៃពាក្យ "បោសសំអាត" និងតម្រូវការបោសសម្អាតគ្រាប់បែកចង្កោមនិងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗ (តម្រូវការបោសសម្អាតមីនប្រឆាំងមនុស្ស/មីនប្រឆាំងរថក្រោះមានចែងនៅក្នុងស្តង់ដាជំពូក០៦)។ ប្រសិនបើការស្រាវជ្រាវរកឃើញថាមានមីនប្រឆាំងមនុស្ស/មីនប្រឆាំងរថក្រោះតម្រូវការបោសសម្អាតមីនត្រូវបានអនុវត្ត ។

## ២.វាក្យស័ព្ទនិងនិយមន័យ

សទ្ទានុក្រម និងនិយមន័យដែលបានប្រើប្រាស់នៅក្នុងស្តង់ដានេះ មានចែងនៅក្នុងស្តង់ដាជំពូក ៣០។

## ៣.តម្រូវការដាក់លាក់សម្រាប់ការបោសសម្អាត

ដីដែលត្រូវបានទទួលស្គាល់ថា "បោសសំអាតរួច" នៅពេលដែលប្រតិបត្តិករបោសសម្អាតអះអាងថាគ្រាប់បែកចង្កោមនិងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗត្រូវបានយកចេញនិង/ឬបំផ្លាញចោលពីតំបន់ណាមួយទៅជម្រៅដែលបានកំណត់ជាក់លាក់ នៅក្នុងស្តង់ដានៃការបោសសម្អាតនេះ និងរាល់ដំណើរការគ្រប់គ្រងគុណភាពត្រូវបានអនុវត្ត និងកត់ត្រាពេញលេញ។

ចំពោះជម្រៅដែលត្រូវបោសសម្អាត ត្រូវអនុវត្តតាមស្តង់ដាដែលបានឯកភាពគ្នា ប៉ុន្តែប្រភេទគ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗ គប្បីត្រូវធ្វើការវាយតំលៃពីកម្រិតគម្រាមកំហែងក្នុងតំបន់នោះរួមមានប្រវត្តិ និងទិន្នន័យស្រាវជ្រាវ ឬព័ត៌មានផ្សេងៗដែលអាចជឿទុកចិត្តបានដើម្បីកំណត់ជម្រៅបោសសម្អាតនិងសិក្សាវាយតម្លៃលើគោលបំណងប្រើប្រាស់ដី។

ខាងក្រោមជាតម្រូវការនៃជម្រៅអប្បបរិមាដែលត្រូវធ្វើការបោសសម្អាតនៅប្រទេសកម្ពុជា:

- គ្រាប់បែកចង្កោម:២០សម
- សំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងៗ:កំណត់ដោយផ្អែកលើកម្រិតការគម្រាមកំហែងដែលអាចមាន និង គោលបំណងប្រើប្រាស់ដី។

ចំពោះការងារបោសសម្អាតដែលពាក់ព័ន្ធនឹងការគម្រាមកំហែងដោយសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលកប់ជ្រៅក្នុងដី ហើយវាយតម្លៃថាមានគ្រោះថ្នាក់ឧបករណ៍ឯកទេសរាវរកគ្រាប់ដូចជាម៉ាស៊ីនរាវរកលោហធាតុ (Large Loop Detector) ម៉ាញ៉េតូម៉ែទ័រ/(Magnetometers) និងបច្ចេកវិជ្ជាទីតាំងភូមិសាស្ត្រ គួរយកមកពិចារណាដើម្បីប្រើប្រាស់។

ប្រតិបត្តិករបោសសម្អាតត្រូវធានាថារាល់ឧបករណ៍ដែលយកមកប្រើប្រាស់ អាចរាវរកទៅតាមជម្រៅដែលតម្រូវឲ្យធ្វើការបោសសម្អាតនៅប្រទេសកម្ពុជា។គ្រប់ម៉ាស៊ីនរាវទាំងអស់ត្រូវធ្វើការសាកល្បង និងកត់ត្រាប្រចាំថ្ងៃដើម្បីធានាថាម៉ាស៊ីនទាំងនោះអាចបំពេញបានតាមតម្រូវការជម្រៅបោសសម្អាត។ ចំពោះម៉ាស៊ីនដែលមិនដំណើរការល្អនៅពេលធ្វើការសាកល្បងប្រចាំថ្ងៃត្រូវយកចេញ និងធ្វើការជួសជុលត្រូវធ្វើការសាកល្បងម៉ាស៊ីនទៅលើចំណុចគោលដៅជាក់លាក់ក្នុងជម្រៅអប្បបរិមា។

## ៤-ការធ្វើគំរោងផែនការបោសសម្អាតថ្នាក់ជាតិ

ដំណើរការនៃការធ្វើផែនការបោសសម្អាត សំដៅធានាថាភារកិច្ចដ៏សមរម្យត្រូវបានជ្រើសរើសសំរាប់កិច្ចប្រតិបត្តិការបោសសម្អាត ដែលក្នុងនោះការប្រើប្រាស់ដីក្រោយពេលបោសសម្អាតរួច និងអ្នកទទួលផលត្រូវបានកំណត់នូវកម្រិតគ្រោះថ្នាក់ពិតប្រាកដព័ត៌មានបច្ចេកទេស និងវិសាលភាពនៃការងារត្រូវបានបញ្ជាក់ ព្រមទាំងកត់ត្រាច្បាស់លាស់ ហើយដំណើរការគ្រប់គ្រងគុណភាព និងប្រសិទ្ធភាពនៃការបោសសម្អាតត្រូវបានអនុវត្ត។

## ៤.១សុពលភាពនៃភារកិច្ចបោសសម្អាត និងការជ្រើសរើសភារកិច្ច

ត្រូវធានាថាដីដែលបានមកពីការស្នើសុំបោសសម្អាត អនុលោមទៅតាមការចាត់អាទិភាពថ្នាក់ជាតិ និងខេត្ត ព្រមទាំងមានផលប៉ះពាល់សេដ្ឋកិច្ច-សង្គមកម្រិតខ្ពស់ទៅលើសហគមន៍មូលដ្ឋានជាការចាំបាច់។ ការវាយតំលៃក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ដែលទទួលផល និងគណៈកម្មាធិការការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីនត្រូវអនុវត្តដើម្បីធានាថាដីដែលបានបោសសម្អាតរួច ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ត្រឹមត្រូវ និងមាននិរន្តរភាព ហើយការប្រើប្រាស់ដីក្រោយការបោសសម្អាតរួច ត្រូវបានកំណត់យ៉ាងច្បាស់លាស់។

## ៤.២ ការធ្វើផែនការនៃការងារបោសសម្អាត

ការស្រាវជ្រាវបច្ចេកទេសត្រូវផ្តល់ព័ត៌មានបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើអោយការបោសសម្អាតមានប្រសិទ្ធភាព និងសុវត្ថិភាពទៅលើតំបន់ដែលត្រូវបានបញ្ជាក់ថាមានការគម្រាមកំហែងពិតប្រាកដ។ ចំពោះព័ត៌មានជាក់លាក់ដូចជាប្រភេទ និងជម្រៅ ស្ថានភាពភូមិសាស្ត្រ លក្ខណៈដី ជាពិសេសដីដែលមានសារធាតុផ្សេងៗរួមមានកម្ទេចអំបែងដែក និងកម្រិតព្រៃ/ស្មៅ គឺជាកត្តាសំខាន់សម្រាប់អោយអ្នកគ្រប់គ្រងធ្វើការពិចារណានៅពេលរៀបចំផែនការបោសសម្អាត។ ការបោសសម្អាតគ្រាប់បែកចង្កោម ត្រូវបានអនុញ្ញាតអោយធ្វើតែក្នុងតំបន់មានគ្រោះថ្នាក់ពិតប្រាកដបន្ទាប់ពីការស្រាវជ្រាវបច្ចេកទេស។ ការបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀត មិនចាំបាច់ធ្វើដោយការស្រាវជ្រាវបច្ចេកទេសទេ។

ការរៀបចំផែនការបោសសម្អាត ត្រូវរាប់បញ្ចូលទាំងឧបករណ៍ និងវិធីសាស្ត្របោសសម្អាតដែលត្រូវប្រើនៅតាមផ្នែកនីមួយៗនៅក្នុងការដ្ឋាន ដែលអាចមានកម្រិតគម្រាមកំហែងខុសៗគ្នា និងជម្រៅដែលតម្រូវអោយបោសសម្អាត។

# ៥. ការទំនាក់ទំនងសហគមន៍

អ្នកទទួលផលពីកម្មវិធីបោសសម្អាតត្រូវមានទំនុកចិត្តថា ដីដែលបានបោសសម្អាតរួចមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់។ ការចូលរួមរបស់សហគមន៍ក្នុងការកំណត់ផលប៉ះពាល់ និងផលប្រយោជន៍នៃការប្រើប្រាស់ដីត្រូវបានអនុវត្តតាមរយៈការពិគ្រោះយោបល់ជាមួយ អ្នកទទួលផល សហគមន៍ គណៈកម្មាធិការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន និងភ្នាក់ងារអភិវឌ្ឍន៍នានា។

សហគមន៍មូលដ្ឋានគួរទទួលបាននូវព័ត៌មានអំពីសកម្មភាព និងដំណើរការវិវឌ្ឍន៍នៃការបោសសម្អាតតាមរយៈការផ្តល់ព័ត៌មាន និងការពន្យល់ជាប្រចាំពីប្រតិបត្តិករបោសសម្អាតក្នុងអំឡុងពេលប្រតិបត្តិការផងដែរ។ ការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការបោសសម្អាត គឺជាសកម្មភាពមួយត្រូវបានត្រួតពិនិត្យ ដែលជាផ្នែកមួយនៃ

ដំណើរការគ្រប់គ្រងគុណភាព។ ប្រសិនបើសហគមន៍មិនពេញចិត្តទៅលើដំណើរការបោសសម្អាត បញ្ហានោះនឹងត្រូវបញ្ជូនអោយក្រុមការងារផែនការសកម្មភាពកម្ចាត់មីនដោះស្រាយ។

## ៦. គុណភាពការបោសសម្អាត

ខាងក្រោមនេះនឹងត្រូវបានបំពេញនៅក្នុងប្រទេសកម្ពុជាដោយ:

ក) ការប្រើប្រាស់ប្រតិបត្តិករបោសសម្អាតដែលមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ដែលមានសមត្ថភាពបោសសម្អាតតាមជំនាញផ្សេងៗដូចជាការបោសសម្អាតកម្ទេចសំណល់ជាតិផ្ទុះពីសង្គ្រាម (លិខិតបញ្ជាក់មានលក្ខណៈជាក្រុមហ៊ុនធ្វើពាណិជ្ជកម្ម ឬអង្គការក្រៅរដ្ឋាភិបាល) ការបោសសម្អាតដោយដៃ បោសសម្អាតដោយប្រព័ន្ធគ្រឿងចក្របោសសម្អាតដោយសត្វ លិខិតបញ្ជាក់ពីការហ្វឹកហ្វឺន/អប់រំយល់ដឹងពីមីន និងក្រុមទំនាក់ទំនង។

ខ) ការប្រើប្រាស់ឧបករណ៍ ដែលស្របទៅតាមតម្រូវការបោសសម្អាត និងធានាថាគ្រប់ម៉ាស៊ីនរាវមីនត្រូវបានធ្វើការសាកល្បង និងកត់ត្រាទុកជារៀងរាល់ថ្ងៃ។

គ) ការធ្វើផែនការដែលមានប្រសិទ្ធភាពសម្រាប់ការងារបោសសម្អាត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបច្ចេកទេស និងតម្រូវការនៃជម្រៅបោសសម្អាតដែលបានកំណត់។

ឃ) ប្រើប្រាស់របៀបគ្រប់គ្រងជាក់ស្តែង និងអនុវត្តច្បាប់សុវត្ថិភាព នីតិវិធីប្រតិបត្តិការ ដែលមានលក្ខណៈសមស្រប និងមានប្រសិទ្ធភាព។

ង) ការគ្រប់គ្រងគុណភាពផ្ទៃក្នុងការត្រួតពិនិត្យ និងការកត់ត្រាដោយប្រតិបត្តិករបោសសម្អាតនិងអង្គភាពចំណុះ។

ច) ការគ្រប់គ្រងគុណភាពពីខាងក្រៅនិងត្រួតពិនិត្យដោយអាជ្ញាធរមីន។

ឆ) ការធ្វើការត្រួតពិនិត្យដីក្រោយការបោសសម្អាត ដោយអនុលោមតាមស្តង់ដាជាតិ។

## ៧. កិច្ចសន្យា និងកិច្ចព្រមព្រៀងបោសសម្អាត

កិច្ចសន្យានិង/ឬកិច្ចព្រមព្រៀងបោសសម្អាត គួរតែព្រាងបន្ទាប់ពីការប្រើប្រាស់ដីក្រោយការបោសសម្អាតត្រូវបានកំណត់ អ្នកទទួលផលត្រូវបានបញ្ជាក់ ហើយបើអាចគឺបន្ទាប់ពីការស្រាវជ្រាវបច្ចេកទេសត្រូវបានធ្វើឡើង។ ការរៀបចំកិច្ចសន្យា ឬកិច្ចព្រមព្រៀង គួបញ្ជាក់ពីតំបន់ និងជម្រៅដែលត្រូវបោសសម្អាត ព្រមទាំងតម្រូវការសម្រាប់ធ្វើការត្រួតពិនិត្យដីក្រោយពេលបោសសម្អាត។ តម្រូវការទាំងនេះ គួរត្រូវបានគូសបញ្ជាក់ដោយពិគ្រោះយោបល់ និងការយល់ព្រមជាមួយអាជ្ញាធរមីនក្នុងអំឡុងពេលរៀបចំកិច្ចសន្យា ឬកិច្ចព្រមពៀង។

តម្រូវការនៃជម្រៅដែលត្រូវធ្វើការបោសសម្អាត អាចកែតម្រូវទៅតាមការវិវឌ្ឍន៍នៃការងារបោសសម្អាតនិងត្រូវបញ្ជាក់ផងដែរនៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងបោសសម្អាត។ រាល់ការធ្វើវិសោធនកម្មត្រូវមានការពិគ្រោះយោបល់ និងឯកភាពពីអាជ្ញាធរមីន គណៈកម្មាការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន។ តម្រូវការនៃជម្រៅបោសសម្អាតត្រូវធ្វើការពិនិត្យឡើងវិញ និងកត់ត្រាទុកបើសិនជាផែនការប្រើប្រាស់ដីមានការផ្លាស់ប្តូរ។

ចំពោះកិច្ចសន្យាក្រុមហ៊ុនវិញ នៅពេលដែលលទ្ធផលដីពុំតម្រូវឲ្យធ្វើការបោសសម្អាតទាំងស្រុង នោះកិច្ចសន្យាបោសសម្អាត ឬលិខិតបញ្ជាក់ការបោសសម្អាតត្រូវបញ្ជាក់ពីអ្វីដែលបានអនុវត្ត។ ប្រសិនបើតម្រូវការបោសសម្អាតទាំងស្រុងមិនត្រូវបានអនុវត្តទេ តំបន់នោះពុំចាត់ទុកថាជាតំបន់បោសសម្អាតរួចឡើយ។

## ៨. ការទទួលខុសត្រូវ និងភារកិច្ច

### ៨.១ ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

ក) ផ្តល់ប្រឹក្សាលើស្តង់ដានិងគោលការណ៍ណែនាំសម្រាប់ការធានាគុណភាព និងការត្រួតពិនិត្យគុណភាព ដែលត្រូវអនុវត្តចំពោះកិច្ចសន្យា និងកិច្ចព្រមព្រៀងបោសសម្អាត។

ខ) ផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណដល់ប្រតិបត្តិករបោសសម្អាតមីន។

គ) ថែរក្សាការចុះបញ្ជីផែនទីដីដែលបានបោសសម្អាតរួច និងដីដែលមិនទាន់បានបោសសម្អាត ដើម្បីបង្ហាញពីស្ថានភាពដីដែលមានគ្រាប់ ឬតំបន់សង្ស័យនីមួយៗ។

ឃ) ត្រួតពិនិត្យប្រតិបត្តិករបោសសម្អាត និងអង្គភាពចំណុះ ដោយអនុលោមតាមស្តង់ដាជំពូក០៣ និងតាមតម្រូវការនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងបោសសម្អាតដែលពាក់ព័ន្ធ។

ង) ថែរក្សានិងផ្តល់ដល់ភាគីពាក់ព័ន្ធតាមផ្លូវច្បាប់នូវឯកសារដែលបានចុះតាមដាននិងត្រួតពិនិត្យគុណភាពដីតាមការដ្ឋាន។

### ៨.២ ការទទួលខុសត្រូវរបស់ប្រតិបត្តិករ

ក) ទទួលបានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណពីអាជ្ញាធរមីន។

ខ) អនុវត្តនីតិវិធីបោសសម្អាត អនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា និងបទដ្ឋានប្រតិបត្តិការរបស់ខ្លួន។

គ) ថែរក្សា និងរៀបចំអោយមានឯកសារបោសសម្អាតឲ្យបានគ្រប់គ្រាន់ និងមានបញ្ជាក់ពីពេលវេលាដូចដែលបានកំណត់ដោយអាជ្ញាធរមីន។

ឃ) អនុវត្តការគ្រប់គ្រងជាក់ស្តែង និងនីតិវិធីប្រតិបត្តិការសម្រាប់បោសសម្អាតដីទៅតាមតម្រូវការដែលបានកំណត់នៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀង។

### ៨.៣ ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ

ភ្នាក់ងារម្ចាស់ជំនួយត្រូវទទួលខុសត្រូវក្នុងការធានាថា គម្រោងកម្មវិធីដែលបានផ្តល់ថវិកា ត្រូវបានចាត់ចែងយ៉ាងមានប្រសិទ្ធភាព និងសុវត្ថិភាពដោយអនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា។ ម្ចាស់ជំនួយក៏ទទួលខុសត្រូវក្នុងការធានាថាគម្រោងដែលបាននឹងផ្តល់ថវិកានោះ ស្របទៅនឹងអាទិភាពជាតិ និងខេត្តតាមរយៈអាជ្ញាធរមីន និងគណៈកម្មាធិការការសកម្មភាពកម្ចាត់មីនខេត្ត-ក្រុង ក្រុមការងារផែនការសកម្មភាពកម្ចាត់មីន។ ការទទួលខុសត្រូវនេះ រួមទាំងការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់លើការកំណត់គម្រោងបោសសម្អាត ការបង្កើតឯកសារកិច្ចព្រមព្រៀង និងធានាថាប្រតិបត្តិករបោសសម្អាតមីនដែលត្រូវជ្រើសរើសអោយអនុវត្តកិច្ចព្រមព្រៀងទាំងនោះ អនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ព្រមទាំងស្តង់ដានានាដែលចេញដោយអាជ្ញាធរមីន។

**៨.៤ ការទទួលខុសត្រូវរបស់អតិថិជន**

ក)ជ្រើសយកប្រតិបត្តិករបោសសម្អាតណាដែលមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណត្រឹមត្រូវ។

ខ)ធានាក្នុងការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមីន លើតម្រូវការបោសសម្អាត។

គ) ធានាថារបាយការណ៍បោសសម្អាត និងលិខិតបញ្ជាក់នានា ត្រូវបានបញ្ជូនមកអាជ្ញាធរមីនទាន់ពេល ដើម្បីកត់ត្រានិងរក្សាទុកក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ។

ភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**ព្រំ សុភមង្គល**